# កម្មវិធីគូស្នេហ៍អមតៈ

COUPLE AMTAK PROGRAM

## ១. សេចក្តីផ្តើម

កម្មវិធីនេះគឺផ្តល់ជូនតែគូស្រករដែលមានអត្តសញ្ញាណក្នុងការបញ្ជាក់ថា ពិតជាបានស្រលាញ់គ្នា យល់ចិត្តគ្នា មានឆន្ទៈបង្កើតជាគ្រួសារថ្មីរួមគ្នា និងបានទទួលស្គាល់ពីឪពុកម្តាយទាំងសងខាង ព្រមទាំងមានការត្រៀមខ្លួនរួចជាស្រេចក្នុងការបង្កើតផែនការជីវិត ថាតើនឹងត្រូវសិក្សាស្វែងយល់យ៉ាងណា អំពីដំណើរនៃជីវិតអាពាហ៍ពិពាហ៍ ដែលនៅក្នុងពេលបច្ចុប្បន្ននេះកំពុងតែប្រឈមយ៉ាងខ្លាំងទៅលើបញ្ហានៃការ ឈ្លោះប្រកែកគ្នា មិនយល់ពីតម្រូវការគ្នាទៅវិញទៅមក មិនចេះឲ្យតម្លៃគ្នាទៅវិញទៅមក មិនមានគោលជំហរដឹកនាំថែរក្សាគ្រួសារ មិនបានសិក្សាស្វែងយល់បន្ថែមពីការថែរក្សារសុខភាពបន្តពូជរបស់ដៃគូជីវិតរបស់ខ្លួន មិនមានគោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ បញ្ហាសេដ្ឋកិច្ចសង្គម សម្ភារៈនិយម ជំនឿនិយម និងបញ្ហាផ្សេងៗទៀត ដែលបង្ករឲ្យជីវិតអាពាហ៍ពិពាហ៍ចាប់ផ្តើមរស់នៅមិនចុះសម្រុងនឹងគ្នារហូតដល់ការលែងលះគ្នា។

## ២. គោលបំណង (Purpose)

កម្មវិធីនេះផ្តល់ជូនការរៀបចំមង្គលការដល់គូស្រករចំនួន២គូ ដើម្បីជាការរួមចំណែកនៅក្នុង៖

1) សកម្មភាពសង្គម

   To involve in social activities

2) ចូលរួមអភិរក្សទំនៀមទម្លាប់ប្រពៃណីអាពាហ៍ពិពាហ៍ខ្មែរ

   To conserve Khmer Traditional Wedding

3) លើកកម្ពស់ និងអោយតម្លៃសីលធម៌សង្គម សំរាប់បុរស និងនារី ដោយស្តែងចេញពីសេចក្តីស្រលាញ់ដែលអាចឈានដល់ការរៀបអាពាហ៍ពិពាហ៍ដោយស្របច្បាប់

   To support social morality to couples whose hearted love is to marry legally.

4) បង្កើនសមត្ថភាពបុរស និងនារីឲ្យមានការទទួលខុសត្រូវសម្រាប់ដំណើរជីវិតអាពាហ៍ពិពាហ៍

   To enhance lady and gentleman's capacity to take action for wedding life.

## ៣. ការផ្តល់ជូន (Offer for free)

៣.១ សិក្សាគម្រោងចំណាយការរៀបចំពិធីអាពាហ៍ពិពាហ៍ជូនគូស្រករ

Prepare budget plan for the whole process of wedding to couples

៣.២ ផ្តល់ជូនការជ្រេញពេលាកំណត់ថ្ងៃរៀបអាពាហ៍ពិពាហ៍សម្រាប់គូស្រករ

Offer for selecting the wedding date for couples

៣.៣ រៀបចំលិខិតអញ្ជើញភ្ញៀវទៅតាមចំនួនភ្ញៀវរបស់គូស្រករ

Prepare the letter of invitation

៣.៤ ផ្តល់កញ្ចប់សម្លាងជូនគូស្រករតម្លៃ ១,៨០០ ដុល្លារ

Offer full set of $1,800 costume packages for couple

៣.៥ រៀបចំម្ហូបអាហារទទួលភ្ញៀវសម្រាប់ពិធីរៀបអាពាហ៍ពិពាហ៍ចំនួន៣៥តុ

Offer full set of wedding party reception for food 35 tables

៣.៦ រៀបចំភេសជ្ជៈសម្រាប់ពិធីរៀបអាពាហ៍ពិពាហ៍ចំនួន៣៥តុ (ស្រាបៀរ, ទឹកក្រូច, ទឹកផ្លែឈើ, ទឹកសុទ្ធ)

Offer full set of wedding party reception for beverage 35 tables ( beer, Juice, water)

៣.៧ រៀបចំកញ្ចប់ថតរូប (ថតស្ទូឌីយោនៅសិរីមង្គល, ថតសន្លឹក, ថតវីដេអូ)

Offer photo package ( Sereimongkul studio, fix-photo, video)

៣.៨ រៀបចំរោងពិធីសម្រាប់ពិធីអាពាហ៍ពិពាហ៍(រោង, តុ ,កៅអី, ម៉ាស៊ីនភ្លើង,ឧបករណ៍បំពងសំឡេង,)

Prepare equipments for wedding program (tent, table, chairs,....)

៣.៩ រៀបចំជំនួន និងវត្ថុអនុស្សាវរីយ៍សម្រាប់ក្នុងពិធី

Prepare dowry and gifts for the program

៣.១០ ផ្តល់ចំណងដៃទាំងអស់ជូនដល់គូស្វាមីភរិយា

Give all money from wedding party reception to couples

៣.១១ ផ្តល់សម្ភារៈប្រើប្រាស់ផ្នែកវិជ្ជាមេផ្ទះសម្រាប់គូស្វាមីភរិយា (ចានឆ្នាំង, ចង្ក្រាន, ទឹកត្រី, ទឹកស៊ីអ៊ីវ, ខ្នើយកន្ទេល, មុងភួយជាដើម)

Offer house accessories to couples after the finished wedding

៣.១២ និងផ្តល់ជូនដំណើរក្រេបទឹកឃ្មុំដល់គូស្រករបន្ទាប់ពីរៀបអាពាហ៍ពិពាហ៍រួចរាល់

Offer full set of honeymoon trip after finishing married day

## ៤. លក្ខខណ្ឌចូលរួម (Conditions)

៤.១ គូស្រករត្រូវតែជាជនជាតិខ្មែរហើយរស់នៅក្នុងប្រទេសកម្ពុជា

Couples are cambodians

៤.២ គូស្រករត្រូវមានសៀវភៅគ្រួសារ ឬអត្តសញ្ញាណប័ណ្ណ ឬសំបុត្រកំណើត, លិខិតបញ្ជាក់កិរិយាមាយាទ និងលិខិតបញ្ជាក់ភាពនៅលីវ (បុរសពោះម៉ាយ ឬស្ត្រីមេម៉ាយមិនអនុញ្ញាត)

Couples must hold family record books or Identity card or certification of birth

៤.៣ គូស្រករត្រូវមានអាយុ (នារីអាយុចាប់ពី១៨ឆ្នាំ និងបុរសអាយុចាប់ពី២០ឆ្នាំ)

Couples must be from 18 years old for women and 20 years old for men

៤.៤ គូស្រករត្រូវមានលិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានស្តីអំពីការស្នាក់នៅអចិន្ត្រៃ

Family condition of couples is required to be certified by the local authority of living location

៤.៥ អ្នកដែលចូលរួមបានគឺមហាជនទូទៅ

The application is open for all people.

## ៥. និតិវិធី និងដំណើរការ (Rules and Processes)

៥១. ជូនដំណឹងកម្មវិធីនេះ តាមរយៈទំព័របណ្តាញសង្គម (www.facebook.com/sereimongkulwedding (និង គេហទំព័រ (www.sereimongkul.com.kh) របស់ក្រុមហ៊ុនសិរីមង្គល សម្រាប់ទូទាំងប្រទេស ។

Promote this event via FB and website of Sereimongkul

៥.២ បេក្ខភាពដែលចូលរួមត្រូវបំពេញពាក្យស្នើសុំ (ប្រវត្តិរូបសង្ខេប៖ ឈ្មោះ រូបថតគូស្រករ ទីលំនៅបច្ចុប្បន្ន អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ និងលេខទូរសព្ទទំនាក់ទំនង) ដែលអាចទាញយកចេញពីគេហទំព័ររបស់សិរីមង្គលតាម http://www.sereimongkul.com.kh/pro/map.pdf។

All applicants are required to fill up the Application Form with consist of information (backgrounds such as names, photos, addresses , IDs, family books, and contact numbers) which can dowload from http://www.sereimongkul.com.kh/pro/map.pdf.

៥៣. បេក្ខភាពដែលចូលរួមត្រូវរៀបចំធ្វើផែនការជីវិតសម្រាប់គ្រួសារថ្មីរបស់ខ្លួន ដោយប្រើប្រាស់ទម្រង់ឬឯកសារផ្ទាល់ខ្លួន។

All applicants are required to prepare the Llife Plan for their new family by using personal Format or document.

៥.៤ បេក្ខភាពត្រូវដាក់ពាក្យស្នើសុំ និងផែនការជីវិត មកកាន់ការិយាល័យក្រុមហ៊ុនសិរីមង្គល ដែលមានទីតាំងនៅផ្ទះលេខ #១១ ផ្លូវ ២៣០ សង្កាត់ទឹកល្អក់បី ទួលគោក រាជធានីភ្នំពេញ ឬផ្ញើរតាមប្រព័ន្ធអេឡិចត្រូនិចអ៊ីមែល info@sereimongkul.com.kh និងទំនាក់ទំនងមកលេខទូរសព្ទ 016 /017/098/ 099 703 703 ដើម្បីទទួលបានព័ត៌មានបន្ថែម។

All applicants are required to submit the Application Form and Life Plan to Sereimongkul office located at #11, street 230, Teuk Laak III, Toul Kork, Phnom Penh, or e-mail to info@sereimongkul.com.kh and contact to 077 /085/081/ 011 703 703

៥.៤ ដំណើរការក្នុងការជ្រើសរើស៖ (Selecting Process)

1) ធ្វើការវាយតម្លៃលើបេក្ខភាពដែលបានដាក់ពាក្យស្នើសុំត្រឹមត្រូវតាមគោលការណ៍កំណត់ និងមានឯកសារគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌ។

   Evaluate by selecting all applicant's Application Form who were submitted correctly according to the requirements

2) ធ្វើការវាយតម្លៃលើបេក្ខភាពដែលមានផែនការជីវិតសម្រាប់គ្រួសារថ្មីរបស់ខ្លួន ដែលល្អជាងគេ ដោយជ្រើសរើសយកចំនួនប្រាំបេក្ខភាពដើម្បីសម្ភាសន៍ដោយផ្ទាល់។

   Evaluate by selecting all applicant's Life Plan which is the most for five couples to directly take an interview

3) ធ្វើការវាយតម្លៃបេក្ខភាពតាមរយៈការសម្ភាសន៍ផ្ទាល់របស់គណៈកម្មាធិការរៀបចំកម្មវិធី។

   Evaluate by taking an interview directly from program committee

4) ធ្វើការវាយតម្លៃដោយប្រជុំគណៈកម្មាធិការ និងបូកសរុបលទ្ធផលសម្រាប់បេក្ខភាពដែលជាប់

   Evaluate by committee conference and finalize couples who pass an interview

5) លទ្ធផលនឹងធ្វើការផ្សព្វផ្សាយនៅក្នុងកម្មវិធីពិព័រណ៍អាពាហ៍ពិពាហ៍លើកទី០៤ មហោស្រពម្ហូបអាហារខ្មែរលើកទី១៨ និងសម្លៀកបំពាក់ប្រពៃណីលើកទី១៧ ដោយពិធីករ និងពិធីការនី ជាមួយនឹងការផ្តល់ជូនជាលិខិតបញ្ជាក់ពីបេក្ខភាពដែលឈ្នះ និងទទួលបានរង្វាន់គូស្នេហ៍អមតៈ។

   The result will announce and provide the letter on Wedding, Khmer Food 18th and Costume 17th Exhibition, Saturday & Sunday 05th-06th August 2017, Diamond Island Convention and Exhibition Center by Master of ceremony (MC).

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៧

ហត្ថលេខា

**ប្រធានផ្នែកទីផ្សារ និងលក់**

**បានឃើញ និង បញ្ជូនមកអគ្គនាយករងដើម្បីសម្រេច**

**នាយកគ្រប់គ្រងទូទៅ**

**បានឃើញ និង សម្រេច**

**ជ. អគ្គនាយក**

# ពាក្យស្នើសុំកម្មវិធីគូស្នេហ៍អមតៈ

| 3×4 ស្រី | 3×4 ប្រុស |
|---|---|

## <u>ប្រវត្តិរូបគូស្រករ</u>

គោត្តនាម(នារី)៖.............................................អាយុ.........................................................................................

ថ្ងៃខែឆ្នាំកំណើត៖.............................................................................................................................................

ទីកន្លែងកំណើត៖..............................................................................................................................................

គោត្តនាម(បុរស)៖..........................................អាយុ..........................................................................................

ថ្ងៃខែឆ្នាំកំណើត៖.............................................................................................................................................

ទីកន្លែងកំណើត៖..............................................................................................................................................

រយៈពេលស្រឡាញ់គ្នាៈ ......................................................................................................................................

គម្រោងរៀបអាពាហ៍ពិពាហ៍៖ថ្ងៃទី....................ខែ...........................ឆ្នាំ....................................................................

ទីតាំងរៀបអាពាហ៍ពិពាហ៍៖ ខេត្ត.................ក្រុង.........................................................................................

**គោលបំណងរបស់អ្នកស្នើសុំ**

..............................................................................................................................................................................

..............................................................................................................................................................................

..............................................................................................................................................................................

..............................................................................................................................................................................

..............................................................................................................................................................................

ធ្វើនៅ..........................ថ្ងៃទី..............ខែ..............ឆ្នាំ២០១៧

**ហត្ថលេខាសាមីខ្លួន** **ហត្ថលេខាឪពុកម្តាយសងខាង**

| នារី | បុរស | ឪពុកម្តាយ ខាងនារី | ឪពុកម្តាយ ខាងបុរស |
|---|---|---|---|
| ____________ | ______________ | ________________ | ______________ |

**លក្ខខណ្ឌនៃការដាក់ពាក្យ**

- ត្រូវមានពាក្យស្នើរសុំកម្មវិធីគូស្នេហ៍អមតៈ
- ត្រូវមានអត្តសញ្ញាណបណ្ណ សៀវភៅគ្រួសារ រឺសំបុត្រកំណើត
- រូបថតទំហំ ៤x៦ ចំនួន២សន្លឹក នឹង ៣x៤ ចំនួន ២សន្លឹក
- សំណេរអំពីផែនការជិវិតឬផែនការសម្រាប់គ្រួសារ(ការគ្រប់គ្រងគ្រួសារ, ហិរញ្ញវត្ថុ,និង សុខភាពបន្តពូជ)
- ផុតកំណត់នៃការទទួលពាក្យនៅថ្ងៃទី២៨ខែកក្កដាឆ្នាំ២០១៨

សូមមកដាក់ពាក្យនៅការិយាល័យសិរីមង្គល ផ្ទះលេខ១១ ផ្លូវ២៣០ សង្កាត់ទឹកល្អក់៣(០១១/០៨១ ៧០៣ ៧០៣)

*បញ្ជាក់៖ គូស្រករនីមួយៗនឹងមិនត្រូវបានជ្រើសរើសសម្រាប់វគ្គបន្តនោះទេ ប្រសិនបើខ្វះតាមលក្ខខណ្ឌខាងលើ។*